**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ឧត្តមក្រុមប្រឹក្សា ភិបាលកិច្ចខាងរដ្ឋ**

**ក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

លេខ.០១៧.....សណន/កគដ

រាជធានីភ្នំពេញថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០១២

## សេចក្ដីណែនាំ

## ស្ដីពីការអនុវត្តបទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ របស់រាជរដ្ឋាភិបាលស្ដីពីការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ពាក់ព័ន្ធនឹងផ្លូវថ្នល់ ផ្លូវដែក ផ្លូវលំ បឹង ទន្លេ ឆ្នេរ និងទីតាំងសេវាសាធារណៈ

ដើម្បីអនុវត្តបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ ០១បប ស្ដីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងធានាបាននូវបទដ្ឋានរៀបចំដែនដី នគរូបនីយកម្ម ព្រមទាំងរក្សាបាននូវហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គមនិងបរិស្ថាន ឱ្យស្របតាមបទដ្ឋានគតិយុត្តជាធរមាន ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងជាប្រធានគណៈកម្មាធិការរៀបចំដែនដី នគរូបនីយកម្មថ្នាក់ជាតិ សូមធ្វើការណែនាំបន្ថែមក្នុងការធ្វើអត្តសញ្ញាណកម្ម និងចុះវាស់វែងដីដើម្បីធ្វើប្រទានកម្មជូនប្រជាពលរដ្ឋ ដូចតទៅ ៖

១-ត្រូវរក្សាដីផ្លូវសាធារណៈសម្រាប់បម្រើសហគមន៍និងផលប្រយោជន៍សាធារណៈទូទៅឱ្យមានទំហំសមស្រប។

២-ត្រូវរក្សាបឹងធម្មជាតិ ឆ្នេរសមុទ្រ ច្រាំងទន្លេ ប្រឡាយ និងផ្លូវទឹកនានា ដូចជាព្រែក អូរ ស្ទឹង ជាដីសាធារណៈរបស់រដ្ឋ ដោយកំណត់ព្រំប្រទល់តាមការអនុវត្តកន្លងមក។

៣-ត្រូវរក្សាព្រៃសហគមន៍ ដីសហគមន៍ សម្រាប់បម្រើប្រយោជន៍សាធារណៈនាពេលអនាគត ។

៤-ចំពោះតំបន់ដែលមានការកាន់កាប់ប្រមូលផ្ដុំមានលក្ខណៈជាភូមិ ត្រូវរក្សាដីបម្រុងទុកសម្រាប់បំរើផលប្រយោជន៍សាធារណៈ មានជាអាទិ៍ ដីទុកសម្រាប់ការសាងសង់សាលារៀន មណ្ឌលសុខភាព វត្តអារាម ទីសក្ការៈ សួនកំសាន្ត...។ ល។

ការកំណត់ដីខាងលើនេះ ត្រូវផ្អែកលើការព្រមព្រៀងរបស់ប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវរក្សាទុកជាដីសាធារណៈរបស់រដ្ឋ។

អភិបាលខេត្តជាប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត និងអភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធានក្រុមការងារដីរដ្ឋក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវក្នុងការកំណត់ខាងលើនេះ។

សេចក្ដីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងជា**
**ប្រធានគណៈកម្មាធិការជាតិរៀបចំដែនដី នគរូបនីយកម្ម**

**អ៊ឹម ឈុនលឹម**

*ចម្លងជូន៖*

- *ក្រសួង/ស្ថាប័នជាសមាជិក ក្រុមប្រឹក្សាគោលនយោបាយដីធ្លី*
- *ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី*
- *គ្រប់រាជធានី ខេត្ត*

  *ដើម្បីជ្រាប*
- *គ្រប់អគ្គនាយកដ្ឋាននិងអង្គភាពជុំវិញក្រសួង ដ.ន.ស .*
- *គ្រប់មន្ទីរ ដ.ន.ស.ស.រាជធានី ខេត្ត*

  *ដើម្បីអនុវត្ត*
- *ឯកសារ កាលប្បវត្តិ*

**អាស័យដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ**